**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំបែកនាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជានាយកដ្ឋានអាស៊ីទី១និងនាយកដ្ឋានអាស៊ីទី២

-----×××-----

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

# សម្រេច

**មាត្រា១.-**

ត្រូវបានបំបែកនាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាពីរនាយកដ្ឋានគឺ ÷

- នាយកដ្ឋាន អាស៊ី ទី១
- នាយកដ្ឋាន អាស៊ី ទី២ ។

**មាត្រា២.-**

នាយកដ្ឋាន អាស៊ី ទី១ មានភារកិច្ច ÷

- តាមដាននិងធ្វើការងារនយោបាយនិងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេស ដែលជាសមាជិកសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ អាស៊ាន ដោយសហការជិតស្និទ្ធ ជាមួយស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋាន អាស៊ី ទី១ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា៣.-**

នាយកដ្ឋាន អាស៊ី ទី២ មានភារកិច្ច ÷

- តាមដាន និងធ្វើការងារនយោបាយ និងការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសអាស៊ីទាំងអស់ដែលមិនមែនជាសមាជិកសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ អាស៊ាន ដោយសហការជិតស្និទ្ធជាមួយស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋាន អាស៊ី ទី២ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយរឺពីរជាជំនួយការតាមការចាំបាច់ ។

**មាត្រា៤.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពចំណុះនាយកដ្ឋានអាស៊ីទី១ និង នាយកដ្ឋានអាស៊ីទី២ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

២

**មាត្រា៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**ហោ ណាំហុង**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ